**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុប្រជុំ

## ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

ឆ្នាំពីរពាន់ម្ភៃមួយ ខែមករា ថ្ងៃទីបួនម៉ោង៨និង សាមសិបនាទីព្រឹកនៅក្នុងក្រុមហ៊ុន ស៊ុងជីនថេកស្តាយ (ខេមបូឌា)ខូ.,អិលធីឌី ដែលមានអស័យដ្ឋាននៅភូមិ ព្រៃភ្វី ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ បានបើកិច្ចប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារកម្មការនិយោជិតចំនួន ៤៣៥ នាក់(ស្រី៣៣៥)ក្នុងចំណោមកម្មករសរុប ៤៤៣នាក់(ស្រី៣៤៧) រយៈពេល២ខែ គិតចាប់ពី ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០២១ រហូតដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១។

1-**សមាសភាពចូលរួមមានដូចតទៅះ**

១-លោក WU ZHIMU ប្រធានបេឡា ក្រុមហ៊ុន ស៊ុងជីនថេកស្តាយ

២-លោក រស់ សុភក្តិ ប្រធានរដ្ឋបាល ក្រុមហ៊ុន ស៊ុងជីនថេកស្តាយ

៣-លោក គុយ ច័ន្ទណារ៉ា ជំនួយការរដ្ឋបាល ក្រុមហ៊ុន ស៊ុងជីនថេកស្តាយ

៤-លោក លោកស្រី ដែលជាតំណាងកម្មករនឹងថ្នាក់ដឹកនាំក្រុមហ៊ុនស៊ុងជីនថេកស្តាយជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំលោក រស់ សុភក្តិ ដែលជាអ្នកសម្របសម្រួលក្នុងអង្គប្រជុំបានធ្វើការពន្យល់ណែនាំពីការខ្វះខាតវត្ថុធាតុដើមសម្ភារៈ និងការលុបចោលការបញ្ជាទិញ របស់ភ្ញៀវ ដែលបណ្តាលអោយបងប្អូនកម្មករនិយោជិតទាំងអស់គ្មានការងារធ្វើ ព្រមទាំងបញ្ហាការរីករាលដាល ការឆ្លងជម្ងឺកូវីដ-១៩ Covid-19 ទូទាំងសកលលោក និងការណែនាំស្តីពីនីតិវិធីនៃការព្យួរកិច្ចសន្យាការងាររបស់កម្មកករនិយោជិតជូនដល់អង្គប្រជុំទាំងមូលបានជ្រាប។

2-**ក្រោយពីបានឆ្លងកាត់ការប្រជុំ និងពិភាក្សារួចមកភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោមះ**

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៤៣៥នាក់ ដូចមានភ្ជាប់ក្នុងបញ្ជីឈ្មោះជាមួយរយៈពេល ០២ខែ ចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ ដល់ ថ្ងៃទី២៨ ខែកម្ភៈ ឆ្នាំ២០២១ និងត្រូវចូលធ្វើការវិញនៅថ្ងៃទី០១ ខែមិនា ឆ្នាំ២០២១តាមកាលកំណត់។

២-ក្រុមហ៊ុនឯកភាពផ្តល់ប្រាក់ចំនួន ៦០ដុល្លារ(សាមសិបដុល្លារអាមេរិក)ក្នុងពេលព្យួរគឺក្រុមហ៊ុនបានអនុវត្តតាមការណែនាំរបស់ក្រសួងប្រកាសលេខ០៤៥ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

៣-ចំពោះការបើកប្រាក់ព្យួរកិច្ចសន្យាការងារចំនួន ៦០ដុល្លារ ក្នុងរយៈពេលពីរខែខាងលើ គឺត្រូវបើកពីរដង មួយដង ៣០ដុល្លា នៅថ្ងៃទី០៨ នៃបំណាច់ខែនីមួយៗ។

កំណត់ហេតុអង្គប្រជុំនេះត្រូវបានបញ្ចប់ទៅនៅវេលាម៉ោងដប់និងសាមសិបនាទីនាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសយោគយល់ អធ្យាស្រ័យ និងស្និទស្នាលក្រៃលែង។